ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**របាយការណ៍សង្ខេប**

# កិច្ចប្រជុំពេញអង្គសមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹង ជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨

**ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨**

**រៀបចំដោយ: អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ឧបត្ថម្ភដោយ: ថវិកាជាតិ**

## ១. សេចក្តីផ្តើម

មេរោគអេដស៍ គឺជាជំងឺរុំារ៉ៃដែលតម្រូវឱ្យមានការប្រុងប្រយ័ត្នក្នុងការគ្រប់គ្រង ពិសេសពង្រឹងសេវានៃការថែទាំ។ ការធ្វើឱ្យប្រសើរឡើងនៃការប្រកាន់ខ្ជាប់ពីការព្យាបាល និងលទ្ធផលនៃការបង្ក្រាបមេរោគមិនត្រឹមតែធ្វើឱ្យប្រសើរឡើងនៃសុខភាពរបស់អ្នកផ្ទុកមេរោគអេដស៍ប៉ុណ្ណោះទេ ហើយថែមទាំងបង្កើនប្រសិទ្ធភាពនៃការការពារ និងការព្យាបាលព្រមទាំងថយចុះនៃការចំលងមេរោគអេដស៍នៅកម្រិតចំនួនប្រជាជន។

ចាប់តាំងពីខែធ្នូឆ្នាំ២០១២ មកប្រទេសកម្ពុជាបានផ្តួចផ្តើមនូវគោលបំណងលុបបំបាត់ការឆ្លងមេរោគអេដស៍ថ្មីនៅឆ្នាំ ២០២៥ ត្រូវបានគេស្គាល់ថាជា"Cambodia 3.0"។ ជាលទ្ធផល កម្ពុជាមានអត្រាអ្នកផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុ១៥-៤៩ឆ្នាំ បានធ្លាក់ចុះជាខ្លាំងពី ១,៦% នៅឆ្នាំ១៩៩៨ មកត្រឹមតែ០,៥% នៅឆ្នាំ២០១៧ គិតជាចំនួនអ្នកផ្ទុកមេរោគ អេដស៍មានចំនួន ប្រមាណ ៦៨ ៦៧៨ នាក់(សម្រេចបានលើសពីការរំពឹងទុក ដែលថានឹងមានអត្រាអ្នកផ្ទុក មេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យ ១៥-៤៩ឆ្នាំ ចំនួន០,៦%ក្នុងឆ្នាំ២០១៧។ ចំណែកអត្រាអ្នកឆ្លងថ្មីក៏មានការថយចុះផងដែរពី ២១ ០០០ នាក់ ក្នុងឆ្នាំ១៩៩៥ មកនៅចំនួន ៥៧២នាក់ ក្នុងឆ្នាំ២០១៧ និងចំនួន៥៣៨នាក់នៅឆ្នាំ២០១៨ មូលដ្ឋានគ្រឹះនៃការជោគជ័យនេះ មានកត្តាជាច្រើន ពិសេសការប្តេជ្ញាចិត្តគាំទ្រជានយោបាយដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រួមជាមួយនឹងកត្តាគ្រប់គ្រាន់មួយចំនួនដូចជា៖ មានចីរភាពនៃការចូលរួមឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន និង បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។ល។ ដោយមានប្រព័ន្ធតាមដានការរាលដាលមេរោគអេដស៍ និងជំងឺ អេដស៍បានជាប្រចាំ មានស្ថាប័នដឹកនាំ គ្រប់គ្រង និងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានផែនការយុទ្ធសាស្ត្រជាតិតែមួយ និងមានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកប ដោយប្រសិទ្ធភាពខ្ពស់ក្រោមការដឹកនាំរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** រួមជាមួយការខិតខំប្រឹងប្រែងពីគ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការក្រៅរដ្ឋាភិបាលផងដែរ ប្រទេសយើងទទួលបានជោគជ័យជាបន្តបន្ទាប់ ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ និងមានការទទួលស្គាល់ពីថ្នាក់ជាតិ និងអន្តរជាតិ។

ទន្ទឹមការសម្រេចបានជោគជ័យកន្លងមក ការដាក់ចេញនូវគោលនយោបាយក្នុងការធ្វើឱ្យប្រសើរឡើងនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៥សម្រាប់ឆ្នាំ២០១៩-២០២៣ និងអនុវត្តនូវគោលការណ៍នៃការចំណាយដែលមានប្រសិទ្ធិភាពនិងនិរន្តរភាព ក៏ជាកត្តាសំខាន់សម្រាប់ការឈានទៅសម្រេចឱ្យបាននូវការ

បញ្ចប់ ការឆ្លងមេរោគអេដស៍ក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០២៥ តាមការកំណត់របស់គោលនយោបាយជាតិ។

## ២. ពេលវេលា និងសមាសភាពចូលរួម

នាព្រឹកថ្ងៃអង្គារ ១២រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ត្រូវនឹងថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០១៨ ក្រោមការដឹកនាំដោយ **ឯកឧត្តម ទេសរដ្ឋមន្ត្រី អៀង មូលី** ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំពេញអង្គលើកទី២ ប្រចាំឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដោយមាន ការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល ប្រចាំនៅប្រទេសកម្ពុជា។ បន្ថែមពីនេះ **ឯកឧត្តម** បានថ្លែងអំណរគុណចំពោះសមាជិក សមាជិកាដែល បានចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គ និងបានសរសើរលើការខិតខំប្រឹងប្រែង របស់ក្រុមការងារ ដែលបានធ្វើការងារឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ ជាពហុវិស័យ រហូតទទួលបានជោគជ័យជាបន្តបន្ទាប់ក្នុងរយៈពេល៦ខែចុងក្រោយប្រកបដោយចីរភាព និងសូមប្រកាសបើកកម្មវិធីកិច្ចប្រជុំពេញអង្គលើកទី២នេះតាមរបៀបវារៈដែលបានគ្រោងទុក។





## ៣. **សមាជិកចូលរួម** (សមាជិកចូលរួម១៤១នាក់/១៧០នាក់)

- ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង
- ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត
- តំណាងអង្គការសង្គមស៊ីវិល
- តំណាងអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា

## ៤. គោលបំណងនៃកិច្ចប្រជុំ

- **ឯកឧត្តម វេជ្ជ. តែង គន្ធី** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិថ្លែងអំណរគុណដល់សមាជិក សមាជិកាទាំងអស់នៅក្នុងអង្គប្រជុំ និងបានបង្ហាញពីគោលបំណងនៃកិច្ចប្រជុំ គឺពិភាក្សាទៅលើ គោលដៅក្នុងការលុបបំបាត់អេដស៍នៅឆ្នាំ២០២៥។ កិច្ចប្រជុំនេះមានបទបង្ហាញទៅតាមរបៀបវារៈដូចខាងក្រោម៖

  ១. ករណីវិនិយោគសម្រាប់សង្គមស៊ីវិល (CSO Investment Case) និងការសិក្សាការគ្របដណ្តប់នៃមូលនិធិសមធម៌មលើអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ (PLHIV and KP) បង្ហាញជូនដោយ **តំណាងអង្គការ** HP+។
  ២. ផែនទីបង្ហាញផ្លូវ ដើម្បីជានានិរន្តរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា (បង្ហាញដោយ តំណាង UNAIDS)។
  ៣. លទ្ធផលនៃការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍លើកទី៤ (NSP IV reviewed) បង្ហាញជូនដោ **ឯកឧត្តម វេជ្ជ. ឆា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
  ៤. បង្ហាញ និងអនុម័តនូវសេចក្តីសម្រេចចិត្តរបស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៨សម្របសម្រួលដោយ **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រីប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បង្ហាញជូនដោយ **ឯកឧត្តម ឃឹម ឈិនដារ៉េត** ។

## *៥. សុន្ទរកថាបើកកិច្ចប្រជុំដោយ ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*

ជាកិច្ចចាប់ផ្តើមបើកនៃកម្មវិធី **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានសំដែងក្តីសោមនស្សរីករាយជាអតិបរមាដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨**" ដ៏មានសារៈសំខាន់នៅពេលនេះ និងមានមតិស្វាគមន៍ដល់ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ទាំងអស់ដែលបានចូលរួមក្នុងអង្គប្រជុំទាំងមូល។

ឆ្លៀតឱកាសនោះផងដែរ ឯកឧត្តមបានសម្តែងនូវការកោតសរសើរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីដែលបានខិតខំយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីចូលរួមចំណែកដឹកនាំគ្រប់គ្រង និងសម្របសម្រួលការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យប្រយុទ្ធនឹងជំងឺអេដស៍ នៅគ្រប់លំដាប់ថ្នាក់រហូតទទួលបានជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ នៅក្នុងរយៈពេល៦ខែចុងឆ្នាំ២០១៨នេះ តាមរយៈការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលប្រកបដោយចីរភាព ដែលនាំមកនូវសមិទ្ធផលគួរ ជាទីមោទនៈ ដែលអាចត្រួតពិនិត្យបាននូវរាលដាលមេរោគអេដស៍នៅកម្ពុជាឱ្យធ្លាក់ចុះជាបន្តបន្ទាប់។

ឯកឧត្តម ក៏បានជម្រាបអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ ២០១៨ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវប្រារព្ធឡើងជាទៀងទាត់រៀងរាល់៦ខែម្តង ដូច្នេះកិច្ចប្រជុំនាថ្ងៃនេះគឺជាកិច្ចប្រជុំលើកទី២បញ្ចប់ឆ្នាំ២០១៨ ដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពនៃការឆ្លើយតបប្រយុទ្ធនឹងជំងឺអេដស៍៦ខែចុងឆ្នាំ២០១៨ រួមជាមួយ នឹងការពិភាក្សាទៅលើចំណុចខ្វះខាតមួយចំនួន ដែលត្រូវការនូវដំណោះស្រាយតាមរយៈការចូលរួមរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលមានវត្តមាននៅពេលនេះ។ លើសពីនេះអង្គប្រជុំនេះនឹងមានការដាក់ចេញនូវសេចក្តីសម្រេច ដែលជាគោលការណ៍សម្រាប់យកទៅប្រើប្រាស់បន្តក្នុងការអនុវត្តផែនការសកម្មភាពគន្លឹះនៅឆ្នាំ២០១៩។ តាមរបៀបវារៈសម្រាប់កិច្ចប្រជុំនៅថ្ងៃនេះ គឺនឹងមានការបង្ហាញមួយចំនួន ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្តីពីករណីវិនិយោគសម្រាប់សង្គមស៊ីវិល និងការសិក្សាពីការគ្របដណ្តប់មូលនិធិសមធម៌លើអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ និងផែនទីបង្ហាញផ្លូវ ដើម្បីជានានិរន្តរភាពនៃការឆ្លើយតប មេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងលទ្ធផលនៃការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ដើម្បីផ្តល់ជូនដល់អង្គពិធីទាំងមូលបានជ្រាបច្បាស់ ពីការវិនិយោគរបស់សង្គមស៊ីវិលក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ និងផែនទីបង្ហាញផ្លូវក្នុងការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាពីឆ្នាំ២០១៩ ដល់២០២៣។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមក៏បានទាញអារម្មណ៍អង្គប្រជុំថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាគោលការណ៍ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការលុបបំបាត់ជំងឺអេដស៍ តាមរយៈការកំណត់យ៉ាងច្បាស់លាស់នូវគោលដៅសូន្យបីគឺ "គ្មានការឆ្លងជំងឺអេដស៍ថ្មី" "គ្មានការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍" និង "គ្មានការស្លាប់ដោយសារជំងឺអេដស៍" នៅត្រឹមឆ្នាំ២០២៥ដោយត្រៀមសម្រេចគោលដៅ៩០-៩០-៩០ ទាំងស្រុងនៅឆ្នាំ២០២០ និងគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។ ជារួមប្រទេសកម្ពុជាយើងកំពុងតែឈរនៅលើផ្លូវត្រូវ យើងកំពុងតែធ្វើត្រូវក្នុងក្តីសង្ឃឹមពិតប្រាកដឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ ដោយសារតែប្រទេសកម្ពុជាយើងមានកត្តាចាំបាច់ដ៏មាន

ប្រសិទ្ធភាពខ្ពស់រួចទៅហើយ គឺការប្តេជ្ញាចិត្តគាំទ្រផ្នែកនយោបាយដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន រួមជាមួយនឹងកត្តាគ្រប់គ្រាន់មួយចំនួនគឺ មានចីរភាពនៃការចូលរួមឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល ឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។ល។ មានប្រព័ន្ធតាមដានការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍បានជាប្រចាំ មានស្ថាប័នដឹកនាំ គ្រប់គ្រង និងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានផែនការយុទ្ធសាស្ត្រជាតិតែមួយ និងមានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។ ដូច្នេះ អ្វី ដែលកម្ពុជានៅសេសសល់ដើម្បីសម្រេចបាននូវក្តីសង្ឃឹមខាងលើ គឺកម្ពុជានៅកំពុងប្រឈមនឹងបញ្ហាធនធានតែប៉ុណ្ណោះ គឺធនធានមនុស្សដែលទាមទារនូវការកសាងសមត្ថភាពពេញលេញពីយុទ្ធសាស្ត្រវិទ្យាសាស្ត្រថ្មីៗក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ធនធានសម្ភារៈ បរិក្ខារ ក្នុងការប្រើប្រាស់បច្ចេកវិជ្ជាអ៊ីនធឺណែត និងធនធានថវិកាដែលជាបញ្ហាប្រឈមខ្ពស់ជាងគេ ដែលទាមទារនូវការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក/លោកស្រីប្រើប្រាស់គ្រប់លទ្ធភាពទាំងអស់ ក្នុងការចលនាធនធានពីគ្រប់ប្រភពទាំងអស់ រួមជាមួយនឹងការធានាដល់ការចំណាយធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយចៀសវាងឱ្យបាននូវការចំណាយច្រើន ទទួលបានផលតិច ឬការចំណាយជាន់គ្នា។ល។

មុននឹងបញ្ចប់សុន្ទរកថា **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជម្រាបអង្គប្រជុំពីសភាពការណ៍ថ្មីៗទាក់ទងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍នៅលើពិភពលោក ជាពិសេសអាស៊ី-ប៉ាស៊ីហ្វិក ដែល**ឯកឧត្តម**ត្រូវបានបោះឆ្នោតជាប់ជាប្រធាន និងបានសំដែងនូវការសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ណាស់ដែលផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តការរៀបចំ និងអនុវត្តការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នាឆ្នាំ២០១៩ឱ្យបានសមស្របទៅនឹងអនុសាសន៍ដែលបានផ្តល់ជូនពីសម័យប្រជុំពេញអង្គនៅពេលនេះ។

## ៦. បទបង្ហាញ និងដំណើរការកិច្ចប្រជុំ

1. ករណីវិនិយោគសម្រាប់សង្គមស៊ីវិល ( CSO Investment Case ) និងការសិក្សាគ្របដណ្តប់នៃមូលនិធិសមធម៌លើអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ( PLHIV and KP ) **បង្ហាញជូនដោយតំណាងអង្គការ HP+ ៖**
   - ចំពោះបទបង្ហាញនេះត្រូវបានបង្ហាញដោយ**លោកវេជ្ជ. ស្រី មុន្នី** ដែលបានមានមតិស្វាគមន៍ចំពោះសមាជិកក្នុងអង្គប្រជុំ និងបានធ្វើបទបង្ហាញអំពីគោលគំនិតនយោបាយ

មួយចំនួនទាក់ទងទៅនឹងការវិនិយោគនៅក្នុងក្រុមអង្គការសង្គមស៊ីវិល និងការវិភាគអំពីការដាក់បញ្ចូលអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ទៅក្នុងមូលនិធិសមធម៌។

– <u>គោលបំណង</u>: ប្រមូលធនធានក្នុងស្រុកក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ដើម្បីឲ្យអង្គការសង្គមស៊ីវិលមានលទ្ធភាពក្នុងធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ និងដាក់បញ្ចូលជនរងគ្រោះទៅនឹងមេរោគអេដស៍ទាំងអស់ទទួលបានប័ណ្ណសមធម៌។

– <u>មាតិកានៃការបង្ហាញ</u> :

១.ការដាក់បញ្ចូលអ្នករស់នៅជាមួយមេរោគអេដស៍ទៅក្នុងគោលនយោបាយជាតិដូចជាគាំពារសង្គម (បសស មូលនិធិសមធម៌ និងការជានារ៉ាប់រង)

២.ការបង្ហាញខ្ទង់ចំនាយទៅលើការដាក់បញ្ចូលអ្នករស់ជាមួយមេរោគអេដស៍ទៅក្នុងមូលនិធិសមធម៌

៣.គោលនយោបាយក្នុងការផ្តល់មូលនិធិរដ្ឋដល់អង្គការសង្គមស៊ីវិលតាមការវិភាគសេណារីយ៉ូនីមួយៗដើម្បីយកមកអនុវត្ត

៤. បង្ហាញពីតួនាទីសំខាន់របស់ CSO ក្នុងកម្មវិធីបង្ការ ថែទាំ និងគាំទ្រជាមួយក្រុមប្រជាជនគន្លឹះ

៥. រាជរដ្ឋាភិបាលទទួលស្គាល់តួនាទី CSOក្នុងការឆ្លើយតបនឹងHIV/AIDS

៦. ការតស៊ូមតិដើម្បីឲ្យរាជរដ្ឋាភិបាលប្តេជ្ញាចិត្តនិងសម្រេចផ្តល់មូលនិធិដល់ CSOs ធ្វើការងារ HIV/AIDS។

– <u>ជំហានបន្ទាប់</u>

កំណត់រកយន្តការហិរញ្ញប្បទានសម្រាប់CSOsដែលផ្តល់សេវាHIV/AIDS។

2. បទបង្ហាញអំពីផែនទីបង្ហាញផ្លូវដើម្បីជានានិរន្តរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា បង្ហាញជូនដោយ**តំណាងអង្គការUNAIDS៖**

– លោកស្រី Vladanka Andreeva តំណាងអង្គការ **UNAIDS** ដែលមានមតិស្វាគមន៍ និងថ្លែងអំណរគុណចំពោះប្រធានអង្គប្រជុំ និងសមាជិកអង្គប្រជុំ

– បង្ហាញពីការងារដែលបានធ្វើរយៈពេល១ឆ្នាំកន្លះ ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការដៃគូអភិវឌ្ឍទាំងអស់ ក្នុងការរៀបចំនូវផែនទីបង្ហាញផ្លូវ សម្រាប់និរន្តរភាពក្នុងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍។

- ក្នុងរយៈពេល១០ឆ្នាំចុងក្រោយប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយដែលសកលលោកទទួលស្គាល់ថាសម្រេចបានគោលដៅ៩០-៩០-៩០ ក្នុងឆ្នាំ២០១៧ ក្នុងចំណោមប្រទេសទាំង៧នៃពិភពលោកដែល UNAIDs បានលើកឡើង
- បង្ហាញពីកង្វះហិរញ្ញប្បទានខាងក្រៅរបស់អង្គការសង្គមស៊ីវិលទៅលើការងារឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍
- បង្ហាញពីការសហការល្អដែលជាគន្លឹះក្នុងការអភិវឌ្ឍផែនទីបង្ហាញផ្លូវ
- បង្ហាញពីការងារវាយតម្លៃក្នុង២០១៧ទៅលើផ្នែក:

    ១. ការងារក្នុងការផ្តល់សេវា

    ២. ការងាររបស់អង្គការសង្គមស៊ីវិល

    ៣. ផ្នែកហិរញ្ញវត្ថុ
- បង្ហាញពីហានិភ័យចំនួន១៣ចំនុច និងដំណោះស្រាយដែលមាននៅក្នុងឯកសារយោង
- ផែនទីបង្ហាញផ្លូវជាឯកសារមួយក៏ដូចជាឯកសារផែនការយុទ្ធសាស្ត្រជាតិលើទី៥សម្រាប់យកមកអនុវត្តនាពេល៥ឆ្នាំខាងមុខ។

3. លទ្ធផលនៃការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ (NSP IV reviewed) បង្ហាញជូនដោយ**ឯ.ឧ.វេជ្ជ.ឆា ផល្លា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖
    - **ឯកឧត្តម** មានថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំ និងបានបង្ហាញចំនុចសំខាន់ក្នុងការវិភាគទៅលើផែនការយុទ្ធសាស្ត្រលើកទី៤ដែលបានអនុវត្តពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៨៖
        - បរិបទនៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិលើទី៤ (NSP IV)
        - បង្ហាញយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រជាតិក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍លើកទី៤:

        ១. យុទ្ធសាស្ត្រ១.០: បង្ការមេរោគអេដស៍

        ២. យុទ្ធសាស្ត្រ២.០: បង្កើន និងរក្សាគុណភាព, គ្របដណ្តប់ និងការក្សាទុកគ្រប់ជំហានទាំងអស់នៃការថែទាំបន្ត

        ៣.យុទ្ធសាស្ត្រ ៣.០: កាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍និងជំងឺអេដស៍

        ៤.យុទ្ធសាស្ត្រ៤.០: ដឹកនាំ សំរបសំរួលភាគីពាក់ព័ន្ធ កៀរគរនិងបែងចែកធនធាន

៥.យុទ្ធសាស្ត្រ ៥.០: បង្ករនិងបង្កើតបរិស្ថានការគាំទ្រតាមរយៈការយល់ដឹង និងការអនុវត្តច្បាប់និងគោលនយោបាយអោយកាន់តែប្រសើរឡើង

៦.យុទ្ធសាស្ត្រ ៦.០: បង្កើនប្រព័ន្ធតាមដាននិងវាយតំលៃការឆ្លើយតបមេរោគអេដស៍ និង ជំងឺអេដស៍តែមួយ ។

- <u>**សន្និដ្ឋាន**</u>

១. មិនទុកនរណាម្នាក់ចោលឡើយ: អនុវត្តយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល BIACM and CAA-PNTTដើម្បីបញ្ចប់ការរាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥។

២. ការជានាលំហរថវិកា( Fiscal Space ) សម្រាប់បញ្ចប់ការរាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥។

៣. ចំណាយគំហុក( Front Loading Investment )ដើម្បីបញ្ចៀសការការខាតបង់ដ៍ធ្ងន់ធ្ងរនៅពេលអនាគត។

៤. ការបញ្ចូលសកម្មភាពនៃ Sustainability Roadmap ទៅក្នុង NSP V

៥. ការបញ្ជ្រាបការងារអេដស៍ទៅក្នុង RSSH:

…..ផ្តល់សមត្ថភាពនិងលទ្ធភាព OD, RH and HCដើម្បីបញ្ចប់ការរាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥។

…..ពង្រឹងស្ថាប័ន( PSM, Procurement, HR, HMIS, Governance )

៦. ផ្តល់ថវិកានិងការបណ្តុះបណ្តាលសម្រាប់ការបញ្ជ្រាបការងារអេដស៍ទៅក្នុង CDP/CIP (ដោយមានទាំងការបញ្ជ្រាបការងារអេដស៍ទៅក្នុង VCSP(ភូមិឃុំមានសុវត្ថិភាព)។

- ការចំនាយរបស់វិស័យសុខាភិបាលសរុបក្នុងឆ្នាំ២០១៥ មាន១០៥៧លានដុល្លាទៅកម្មវិធីផ្សេងៗដែលមានការងារអេដស៍៥%។

❖ **ការលើកឡើងៈ**

➢ ដាក់បញ្ជ្រាបការងារអេដស៍នៅក្នុងប្រព័ន្ធសុខាភិបាល

➢ ត្រូវពង្រឹងប្រព័ន្ធសុខាភិបាលដូចជា: គុណភាពថ្នាំ ART, បរិមាណថ្នាំ ART និងធនធានមនុស្សក្នុងវិស័យសុខាភិបាល។

- ➢ គួរមានការអប់រំផ្សព្វផ្សាយអំពីមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងកម្មវិធីសំខាន់ៗរបស់ក្រសួងបរិស្ថាន។

4. បទបង្ហាញនិងអនុម័តនូវសេចក្ដីសម្រេចចិត្តរបស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៨សម្របសម្រួលដោយ **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបង្ហាញជូនដោយ **ឯកឧត្តម ឈឹម ឃិនដារ៉េត៖**

ដើម្បីធានានិរន្តរភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជា សម្រាប់រយៈពេល៥ឆ្នាំខាងមុខ និងដោយបានការអនុញ្ញាតពីឯកឧត្តមទេសរដ្ឋមន្ត្រីផងនោះ **ឯ.ឧ. ឈឹម ឃិនដារ៉េត** បានអាននូវសេចក្ដីសម្រេចចិត្តរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់អនុវត្តនាពេលខាងមុខ និងដើម្បីឱ្យកិច្ចប្រជុំធ្វើការពិភាក្សាពិគ្រោះយោបល់។

បន្ទាប់ពីមានការពិភាក្សាយ៉ាងផុលផុសរួចមក ក្រោមការដឹកនាំរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** អង្គប្រជុំបានសម្រេច និងបានដាក់ចេញនូវសេចក្ដីសម្រេចចិត្ត ជាទិសដៅសកម្មភាពការងារដូចខាងក្រោម៖

១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ និងយុទ្ធសាស្ត្រជាតិធានាចីរភាព សម្រាប់ឆ្លើយតបការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បញ្ចូលសកម្មភាពដែលបានលើកឡើងនៅក្នុងផែនទីចង្អុលផ្លូវ នៃការឆ្លើយតបដោយចីរភាពទៅក្នុងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្ដល់ថវិកាអនុវត្តការបញ្ជ្រាបការងារប្រយុទ្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍ និងវិនិយោគឃុំ សង្កាត់។

៤. ក្រសួងសុខាភិបាល និងក្រសួងផែនការត្រូវកំណត់ថាអ្នកផ្ទុកមេរោគអេដស៍ជាក្រុមប្រជាជនងាយរងគ្រោះដែលត្រូវទទួលបានអត្តសញ្ញាណគ្រួសារក្រីក្រ និងមូលនិធិសមធម៌ដែលធានាដល់ការទទួលបានសេវាថែទាំសុខភាព និងការគាំពារសង្គម។

៥. ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកែសម្រួល និងរៀបចំវិធាន និងនីតិវិធីក្នុងការផ្ដល់ថវិកាដើម្បីឱ្យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពមានថវិកាផ្ទាល់សម្រាប់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

៦. ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវទទួលស្គាល់តួនាទីសំខាន់របស់អង្គការសង្គមស៊ីវិលក្នុងការឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍ និងបន្តគាំទ្រឱ្យមានការចូលរួមបន្តទៀតតាមរយៈការផ្តល់មូលនិធិពីរាជរដ្ឋាភិបាល តាមលទ្ធភាពថវិកាជាតិ។

៧. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិត្រូវសិក្សាលំហថវិកា ដើម្បីធានាការអនុវត្តការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបញ្ចប់បញ្ហាអេដស៍នៅក្នុងឆ្នាំ២០២៥។

៨. ក្រសួងសុខាភិបាលត្រូវបន្តពង្រឹងធនធានមនុស្ស ការធ្វើលទ្ធកម្ម ការផ្គត់ផ្គង់ឱសថបរិក្ខារ និង ប្រព័ន្ធព័ត៌មាន ដើម្បីបញ្ជ្រាបការឆ្លើយតបការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព និងធានានិរន្តរភាព។

នៅក្នុងការបង្ហាញពីសេចក្តីព្រាងស្តីអំពីការសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំង ៨ ចំនុចដែលមាននៅក្នុងឯកសារយោង ត្រូវបានសម្រេចជោគជ័យ និងកែសម្រួលចំនុចខ្លះៗ ក្រោមការសម្របសម្រួលដោយ ឯកឧត្តម ប្រធានអង្គប្រជុំ និងសហការជាមួយ ក្រសួង ស្ថានប័ន និងអង្គការសង្គមស៊ីវិល មុនដាក់ជូន រាជរដ្ឋាភិបាលដើម្បីធ្វើការអនុម័ត។

## *៧.* សុន្ទរកថាបិទអង្គប្រជុំដោយ ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតប្រយុទ្ធនឹងជំងឺអេដស៍

ជាកិច្ចចុងបញ្ចប់មុនបិទកម្មវិធី **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នៅក្នុងអង្គប្រជុំដែលបាន សហការគ្នាបានយ៉ាងល្អប្រសើរ។ **ឯកឧត្តមប្រធាន** បានសម្តែងនៅការកោតសរសើរចំពោះគណៈកម្មាធិការ ក្រសួង ស្ថាប័ន ដែលបានទទួលបានថវិការយកមកអនុវត្តកម្មវិធី ឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍រួចហើយ និងបានជម្រុញឲ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រាជធានីខេត្តដែលមានមិនទាន់បានអនុវត្តឲ្យដាក់សំណើរថវិការជូនទៅ រាជរដ្ឋាភិបាលដើម្បីទទួលបានថវិការ យកមកអនុវត្តការងារឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ជាពហុវិស័យ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជូនពរសមាជិកអង្គប្រជុំទាំងអស់ និងក្រុមការងារឱ្យជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

កិច្ចប្រជុំនេះត្រូវបានបញ្ចប់ដោយរលូន និងស្ថិតក្នុងបរិយាកាសអំណោយផល នាវេលាម៉ោង ១២ថ្ងៃត្រង់ទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨

តំណាងក្រុមការងារទទួលបន្ទុករបាយការណ៍

**លោកវេជ្ជ. ទឹម យ៉ាណាត**

បានពិនិត្យត្រឹមត្រូវ

**អគ្គលេខាធិការ**

**វេជ្ជ.តែង គន្ធី**

បានឃើញ និងឯកភាព

**ឯកឧត្តមទេសរដ្ឋមន្ត្រី**

**អៀង_មូលី**

# ឯកសារយោង


1. អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុ ១៥-៤៩ឆ្នាំ របស់UNAIDS. http://www.unaids.org/en/regionscountries/countries/cambodia
2. Spectrum/AEM ឆ្នាំ២០១៦ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ឆ្នាំ ២០១៦
3. ការព្យាករណ៍មេរោគអេដស៍ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ឆ្នាំ ២០១៦
4. បញ្ជីវត្តមានចូលរួមកិច្ចប្រជុំពេញអង្គ នាថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី
5. របៀបវារៈនៃកិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ប្រចាំឆ្នាំ២០១៨_ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី
6. Projected Annual Cost of Coverage of PLHIV under HEF ( Scenario 1-3 ) FY2019 _ Dr. Srey Mony, HP+ presentation_4 Dec 2017
7. ហិរញ្ញប្បទានសម្រាប់សង្គមស៊ីវិលដែលផ្តល់សេវាHIV/AIDS_ Dr. Srey Mony, HP+ presentation_4 Dec 2017